ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំត្រីមាសទី១ ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២០នេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងនៅទូទាំងប្រទេសត្រូវបានបញ្ចប់ដោយសម្រេចធ្វើការដាំដុះបានចំនួន ៥៩៧ ៥០៨ហ.ត ស្មើនឹង១៣០% នៃផែនការចំនួន ៤៥៩ ៥៩៤ហ.ត។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសទី១ ឆ្នាំ២០២០នេះ គឺ បានរៀបចំវេទិកាកសិកម្ម រុក្ខាប្រមាញ់ នេសាទ និងសម្បទានដីសេដ្ឋកិច្ច រៀបចំវេទិកាកសិកម្មឆ្នើម និងកិច្ចប្រជុំសំខាន់ៗ ការទទួលជួបភ្ញៀវជាតិ-អន្តរជាតិ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាច្រើន រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២០ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងត្រីមាសទី១ ឆ្នាំ២០២០នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលបញ្ចប់ផ្នែកដាំដុះរដូវប្រាំងឆ្នាំ២០១៩-២០២០

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំង

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងគិតត្រឹមថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៦០២ ៣៣២ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៤ ២៦៦ហ.ត និងដោយគ្រឿងយន្តមានចំនួន ៥៩៨ ០៦៦ហ.ត តិចជាងឆ្នាំមុនចំនួន ៣០ ៥៧០ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៧៤ហ.ត តិចជាងឆ្នាំមុនចំនួន ៩៨ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៥៩៧ ៥០៨ហ.ត ស្មើនឹង១៣០% នៃផែនការចំនួន ៤៥៩ ៥៩៤ហ.ត លើសឆ្នាំមុនចំនួន ១ ០២៥ហ.ត។

#### ១.២ ការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៩-២០២០

ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានចំនួន ៥៩២ ១២៨ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ២ ៦១៦ ២៥៣តោន។ ទិន្នផលគិតជាមធ្យម ៤,៤១៨តោន/ហ.ត។

#### ១.៣ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៩-២០២០

-ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៣៧ ៦២៦ហ.ត ស្មើនឹង១១៦,១២% នៃផែនការចំនួន ៣២ ៤០៣ហ.ត លើសឆ្នាំមុនចំនួន ២ ៣៦៨ហ.ត

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726.128 / 726 129. Fax: (855) 23-217 320

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧៩ ២៧៤ហ.ត ស្មើនឹង៧៤,៨៨% នៃផែនការចំនួន ១០៥ ៨៧៣ហ.ត តិចជាងឆ្នាំមុនចំនួន ១០ ៣៦៧ហ.ត។

**១.៤ ការនាំចេញអង្ករ**

បរិមាណនាំចេញអង្ករបានចំនួន ២៣០ ៩៤៨តោន មានការកើនឡើងចំនួន ៦០ ១២៧តោន (+៣៥,២០%) ច្រើនជាងបរិមាណនាំចេញត្រីមាសទី១ ឆ្នាំ២០១៩ និងបាននាំចេញទៅកាន់ទិសដៅចំនួន ៥៤ប្រទេស ក្នុងនោះប្រទេសចិនលំដាប់ទី១ (៩២ ៣៤៩តោន) ប្រទេសបារាំងលំដាប់ទី២ (២៣ ៩១៦តោន) ប្រទេសហុងកុងលំដាប់ទី៣ (១២ ៨៩៨តោន) ប្រទេសវៀតណាមលំដាប់ទី៤ (១២ ៤៦៦តោន) ប្រទេសម៉ាឡេស៊ីលំដាប់ទី៥ (១០ ១៧៣តោន) ប្រទេសអូស្ត្រាលីលំដាប់ទី៦ (៩ ៧៨១តោន) ប្រទេសណេដឺឡែនលំដាប់ទី៧ (៩ ៤៧៧តោន) ហុងកុងលំដាប់ទី៨ (៨ ៦៧៦តោន) ប្រទេសអង់គ្លេសលំដាប់ទី៩ (៥ ៨៧០តោន) និងប្រទេសប៉ូឡូញលំដាប់ទី១០ (៥ ៦៥៣តោន) ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៦២ក្រុមហ៊ុន។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤០៥ ៤៨៥ហ.ត ដែលក្នុងនោះៈ ផ្ទៃដីចៀរជ័រមានចំនួន ២៥០ ៧៥០ហ.ត ស្មើនឹង ៦២% និងផ្ទៃដីថែទាំមានចំនួន ១៥៤ ៧៣៥ហ.ត ស្មើនឹង៣៨%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ៥៣ ២៧២តោន កើនចំនួន ៥ ០៨៩តោន ស្មើនឹង១១% ធៀបត្រីមាសទី១ ឆ្នាំ២០១៩។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់សម្រេចបានចំនួន ៥៣ ០៥៧តោន កើនឡើងចំនួន ៤ ៨៦៥តោន ស្មើនឹង ១០% ធៀបត្រីមាសទី១ ឆ្នាំ២០១៩។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃលក់មធ្យមក្នុងខែមីនា ឆ្នាំ២០២០ គឺ១ ៣៩៧ដុល្លារ/តោន ថយចុះចំនួន ១៧ដុល្លារ/តោន ស្មើនឹង១,២១% ធៀបខែមុន និងកើនឡើងចំនួន ៣៥ដុល្លារ/តោន ស្មើនឹង៣% ធៀបខែមីនា ឆ្នាំ២០១៩

- តម្លៃលក់កៅស៊ូជាមធ្យមក្នុងត្រីមាសទី១ ឆ្នាំ២០២០ គឺ១ ៤២០ដុល្លារ/តោន កើនឡើងចំនួន ១៤១ដុល្លារ/តោន ស្មើនឹង១១% ធៀបត្រីមាសទី១ ឆ្នាំ២០១៩

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅចម្ការ គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៤ ៦០០៛ ដល់ ៤ ៨០០៛/គ.ក្រ (ពុំមានការកើនឡើង) និងជ័រកក (DRC 50%) ថ្លៃ១ ៩៥០៛ ដល់ ២ ៥០០៛/គ.ក្រ (ថយចុះចំនួន ១០០៛/គ.ក្រ ធៀបខែមុន) អាស្រ័យតាមតំបន់។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បានទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០១៩ ចំនួន ១៥ផ្ទាំង និងឆ្នាំ២០២០ ចំនួន ៧ផ្ទាំង សម្រាប់ធ្វើការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២០

- បានយល់ព្រមជាគោលការណ៍លើផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ៥កន្លែង លើផ្ទៃដីសរុបទំហំ ២ ០០៥ហ.ត ស្ថិតក្នុងខេត្តស្ទឹងត្រែង និងខេត្តកំពត

- បានចុះពិនិត្យ និងផ្ទៀងផ្ទាត់តំបន់សក្តានុពលព្រៃសហគមន៍ព្រៃឈើប្រាំបីមុម២ មានផ្ទៃដីទំហំ ២៨៣ហ.ត ស្ថិតក្នុងខេត្តកំពង់ស្ពឺ និងសហគមន៍ព្រៃឈើត្រពាំងពិការ ខេត្តស្វាយរៀងមានផ្ទៃដីទំហំ ៤៤៤ហ.ត

- បានផ្តល់ប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ៨៣គ្រឿង និងយានយន្តចំនួន ៦២គ្រឿង ជូនក្រុមហ៊ុនចំនួន ៦ និងអ្នកស្នើសុំចំនួន ២នាក់

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៥ និងអ្នកស្នើសុំចំនួន ៦នាក់ ដែលមានឈើហ៊ុបមូលចំនួន ១ ១២៣ម៣ ឈើអារចំនួន ៤ ៧១១ម៣ ឈើជ្រុងចំនួន ៩៧៥ម៣ ក្រាក់ចំនួន ២៣ម៣ គល់ឈើ

ចំនួន ៣ម$^{៣}$ កូនឈើចំនួន ៨២ ៦៥៧ដើម បង្គោលក្រាក់ចំនួន ៣១១ដើម ជន្លង់ម្រេចចំនួន ១៦៣ដើម ចំនៀរឈើចំនួន ១៣១ដើម អុសចម្រុះចំនួន ២៣ ២១៩ស្ទេរ ជ័រទឹកចំនួន ៣១៨តោន ឬស្សីចំនួន ៦៩៨តោន ពកចំនួន ២០៤គ.ក្រ គល់ឈើចំនួន ៩ ៣៧៦គ.ក្រ ធ្យូងចំនួន ២៤ ៩៦០គ.ក្រ ផ្តៅចំនួន ៣ ០០០គ.ក្រ តុចំនួន ១គ្រឿង ទូចំនួន ៨គ្រឿង កៅអីចំនួន ១២គ្រឿង គ្រែចំនួន ៤គ្រឿង សន្លឹកទ្វារចំនួន ២១សន្លឹក ចំនៀរឈើចំនួន ៣ ១១០សន្លឹក និងចូផ្កាចំនួន ៤គ្រាប់។

**៣.២ ការងារអភិរក្សសត្វព្រៃ**

- បានចុះអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបការជួញដូរសត្វព្រៃចំនួន ១លើក នៅខេត្តរតនគិរី ដោយរឹបអូសសត្វអណ្តើករស់ចំនួន ២ក្បាល សត្វត្រកួតរស់ចំនួន ១ក្បាល និងដោះអន្ទាក់សត្វព្រៃចំនួន ១៥ខ្សែ បន្ទាប់មកក្រុមការងារបានយកសត្វទាំងនោះទៅប្រលែងចូលព្រៃធម្មជាតិវិញក្នុងសហគមន៍ព្រៃឈើវាលថ្មវប្លង់

- បានចុះសិក្សាស្រាវជ្រាវ និងតាមដានវត្តមានសត្វព្រៃចំនួន ១លើក នៅក្នុងតំបន់សហគមន៍ព្រៃអណ្តូងព្រះនាង ខេត្តរតនគិរី ដោយបានកត់ត្រានូវប្រភេទសត្វព្រៃចំនួន ១៤៧ប្រភេទ ក្នុងនោះមានថនិកសត្វចំនួន ៤៣ប្រភេទ បក្សីចំនួន ៦៤ប្រភេទ និងឧរង្គសត្វចំនួន ៤០ប្រភេទ

- បានសហការជាមួយអង្គការ FFI ចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ១០គ្រឿង នៅតំបន់ជួរភ្នំក្រវាញជាលទ្ធផលថតជាប់សត្វព្រៃចំនួន ៩៥ក្បាល ក្នុងនោះមានសត្វដំរីព្រៃចំនួន ១៨ក្បាល ខ្លាឃ្មុំតូច ២ក្បាល ខ្លាពពកចំនួន ១ក្បាល ប្រើសចំនួន ៤ក្បាល ឈ្លូសចំនួន ៩ក្បាល ស្វាត្រោសចំនួន ៥ក្បាល និងជ្រូកព្រៃចំនួន ៥៦ក្បាល

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៤១ច្បាប់ ក្នុងនោះថែរក្សាសត្វត្រចៀកកាំចំនួន ៣៦ច្បាប់ និងថែរក្សាសត្វព្រៃប្រភេទផ្សេងទៀតចំនួន ៥ច្បាប់ ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកោះកុង កំពត បាត់ដំបង ពោធិ៍សាត់ រតនគិរី កំពង់ចាម សៀមរាប បន្ទាយមានជ័យ និងខេត្តកណ្តាល។

**៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ**

- ក្រុមហ៊ុនចំនួន ៧ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨ទីតាំង ស្ថិតនៅក្នុងរាជធានីភ្នំពេញ កំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានសត្វស្វាក្តាមចំនួន ៦០ ៣៥៨ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ១០ ៥៥២ក្បាល ដឹកជញ្ជូនក្នុងស្រុកចំនួន ១ ៥០០ក្បាល និងដឹកជញ្ជូនឆ្លងទៅកាន់ច្រកអន្តរជាតិសម្រាប់នាំចេញទៅក្រៅប្រទេសចំនួន ២ ៣៩៨ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៩១៣ ក្បាល (បក្សីចំនួន ៥៦ប្រភេទ ថនិកសត្វចំនួន ៤៦ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ៧២១ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ៧៧ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ២៨៦ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- តាមដានវាយតម្លៃការអភិរក្សក្រពើប្រចាំឆ្នាំនៅតំបន់អភិរក្សសំខាន់ៗទាំង ០៥ ខាងលើ បានរកឃើញលាមកចំនួន ៩០ សំណាក ដានជើងចំនួន ២៣ កន្លែង និងឃើញក្រពើផ្ទាល់ចំនួន ២២ ក្បាល

- បណ្តុះបណ្តាលបច្ចេកទេសនៃការចិញ្ចឹមមាន់ដល់ប្រជាសហគមន៍ចំនួន ២២៤នាក់ (ស្ត្រី១២៤នាក់) នៅក្នុងខេត្តកោះកុង និងខេត្តពោធិ៍សាត់

- បានជួសជុលផ្លូវដោយក្រាលក្រួសក្រហមទំហំ ១១ ៩៩០ម៉ែត្រការ៉េ និងកាប់ឆ្ការអនាម័យព្រៃទំហំ ១៣ហ.ត នៅក្នុងតំបន់សួនសត្វ។

**៣.៤ ការងារដាំដើមឈើ**

- បាននិងកំពុងថែទាំចម្ការឈើទំហំ ៩៣២ហ.ត ក្នុងនោះចម្ការពូជឈើ ៨៩ហ.ត ឡូត៍បង្ហាញកសិ-រុក្ខកម្មទំហំ ៤៩ហ.ត ចម្ការឈើដាំទំហំ ៧៥៤ហ.ត និងចម្ការរុក្ខទិវា ៩កក្កដា សរុបទំហំ ៤០ហ.ត (ខេត្តកំពត កណ្តាល កំពង់ធំ និងខេត្តក្រចេះ)

- បានដាំឈើជាចម្ការថ្មីប្រចាំឆ្នាំ២០២០ លើផ្ទៃដីទំហំ ១៥០ហ.ត នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំបានឈូសឆាយសម្អាតដីទំហំ ១០ហ.ត

- បាននិងកំពុងថែទាំប្រឡាយប្រវែង ១៨ ០០០ម៉ែត្រ ក្នុងនោះប្រឡាយជីកក្នុងឆ្នាំ២០១៨ ប្រវែង ១០ ០០០ម៉ែត្រ និងឆ្នាំ២០១៩ ប្រវែង ៨ ០០០ម៉ែត្រ នៅខេត្តកំពង់ធំ និងខេត្តព្រះសីហនុ

- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ១៦៦ ១៧៥ដើម ក្នុងនោះថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើនៅទូទាំងប្រទេសចំនួន ៨៦ ៩៨៥ ដើម និងថ្នាលបណ្តុះកូនឈើចំនួន ៦ទីតាំង ស្ថិតនៅក្នុងខេត្តពោធិ៍សាត់ កំពង់ធំ តាកែវ កំពង់ចាម និងខេត្តកណ្តាលចំនួន ២កន្លែង ចំនួន ៧៩ ១៩០ដើម។

### ៣.៥ ការងារនីតិកម្មនិងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ៣៤៤ករណី ដោយពិន័យអន្តរការណ៍ចំនួន ១០៩ករណី និងបញ្ជូនទៅតុលាការចំនួន ២៣៥ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងចំនួន ៣២ម៣ ឈើអារសរុបចំនួន ៦០៥ម៣ (ចំនួន១១២ករណី) ក្រាក់គ្រញូងចំនួន ២ម៣ ផ្ទៃដីព្រៃឈើកាប់រានទំហំ ១២៦ហ.ត នៅខេត្តស្ទឹងត្រែង ក្រចេះ រតនគិរី កំពង់ឆ្នាំង កំពង់ស្ពឺ បន្ទាយមានជ័យ និងខេត្តព្រះវិហារ វត្ថុតាងសត្វព្រៃចាប់ឃាត់ចំនួន ៤៧៤ក្បាល និង ៤៦៤គ.ក្រ ក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើចំនួន ៦ករណី នៅខេត្តរតនគិរី ១ករណី និងខេត្តកោះកុង ១ករណី និងអនុផលព្រៃឈើព្រមទាំងឧបករណ៍ សម្ភារផ្សេងៗទៀត។

### ៣.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំចំនួន ១២កន្លែង នៅក្នុងរាជធានីភ្នំពេញ ខេត្តតាកែវ ស្វាយរៀង រតនគិរី ព្រៃវែង កំពង់ធំ កណ្តាល កំពង់ស្ពឺ កំពង់ចាម និងខេត្តកំពង់ឆ្នាំង

- បានបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ៤កន្លែង ជូនក្រុមហ៊ុន ស៊ូនស៊ូន ហួតត្រេឌីង ឯ.ក មេហ្គា ហ្វឹសផ្លេន ថេសិន លោក លាង ផល្លា និងលោក ឡៅ វៃ

- បានពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ៣កន្លែងជូនក្រុមហ៊ុនហុងកុងហ្វាងយ៉ន ខុងហ្វូ ប៊ីលឌីង មេធៀវៀលវូដ ឯ.ក អង្គរ ផ្លាយវូត ខូអិលធីឌី និងក្រុមហ៊ុនផេភើទ្រី អ៊ិនវេសមេន

- បានចុះប្រមូលចងក្រងទិន្នន័យបរិមាណផលិតផលឈើកែច្នៃ ព្រមទាំងសិក្សាតម្លៃទីផ្សារ និងតម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើប្រចាំឆ្នាំ២០២០ ក្នុងខេត្តក្រចេះ ស្ទឹងត្រែង និងខេត្តមណ្ឌលគិរី

- បាននាំចេញផលិតផលរានទេវតា ឈើកែច្នៃ និងជ័រទឹកទៅក្រៅប្រទេសមានចំនួន ៤០៩ម៣ និងជ័រទឹកចំនួន ១៣០តោន ដោយក្រុមហ៊ុនចំនួន០៥

- បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ៧២២ម៣ ដោយក្រុមហ៊ុនចំនួន៣

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ៥មានបរិមាណឈើកែច្នៃវីនៀរ និងគ្រឿងសង្ហារិមសរុបចំនួន ៨០៦ម៣ និងជ័រទឹកចំនួន ១០៦តោន

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន ២មានបរិមាណឈើកែច្នៃ (Dark Red Meranti) សរុបចំនួន ៨៤៨ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- បានចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន ១ ៩២០ ៩៦៩ ៨១៥រៀល និង ១៨៩ ១៦៦,១៣ ដុល្លារ។

## ៤ ផ្នែកផលិតកម្ម និងបសុពេទ្យបាល

**៤.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្ទូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ។

### ៤.២ ការងារបសុពេទ្យបាល

• លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖ រាជធានី-ខេត្តចំនួន ២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៥០ ១៤០លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពី

សត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៦២ករណី ក្នុងនោះឃាត់ចាប់ចំនួន ១៤ករណី។

- **ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចុះប្រជុំណែនាំបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន ៤ ចុះឃោសនាអប់រំជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន ២ ចុះផ្សព្វផ្សាយជំងឺផ្តាសាយបក្សីនៅតាមបណ្តាខេត្តចំនួន ៦ និងបើកវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រផ្សព្វផ្សាយ និងការបង្កើតសម្ភារៈផ្សព្វផ្សាយនៅខេត្តចំនួន ១ និងចុះប្រជុំផ្សព្វផ្សាយកម្រងលិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្តចំនួន១២។
- **ការងារនីតិកម្ម និងវិវាទ**

- រៀបចំសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម ការផលិត និងធ្វើការលាយផ្សំកំពុងពិភាក្សានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- កំពុងរៀបចំបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វមួយចំនួនទៀត។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៧ក្បាល។ ដោយឡែក នៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ១២២ក្បាល។
- **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ៤ ១៦៥វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តចំនួន ១ ៥០០តោន ស្មើនឹង១២,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៨៧០តោន
- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តចំនួន ៦៩ ៣៥០តោន ស្មើនឹង២០,១០% នៃផែនការចំនួន ៣៤៥ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៩៥០តោន
- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ១៧ ៥១០តោន ស្មើនឹង១២,០៨% នៃផែនការចំនួន ១៤៥ ០០០ តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ១ ៥៩០តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ២៥ ៧៨០តោន ស្មើនឹង២៣,៤៤% នៃផែនការចំនួន ១១០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៧០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៥១ ៨៦៦តោន ស្មើនឹង១៤,៤១% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ កើនឡើងចំនួន ៨ ៦៤៤តោន
- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៣០ ៧៥០ក្បាល ស្មើនឹង១០,២៥% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ កើនឡើងចំនួន ២០០ក្បាល
- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៤៨ ៥០០ ០០០កូន ស្មើនឹង២០,២១% នៃផែនការចំនួន ២៤០ ០០០ ០០០ កូន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ កើនឡើងចំនួនប្រមាណ ៥០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ១៧ ៧៥០តោន ស្មើនឹង២១,៦៥% នៃផែនការចំនួន ៨២ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៩០០តោន
- ផលនេសាទសមុទ្រអនុវត្តបានចំនួន ២ ៦៥០តោន ស្មើនឹង២៩,៤៤% នៃផែនការចំនួន ៩ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ កើនឡើងចំនួន ២០តោន
- ការផលិតទឹកត្រីអនុវត្តបានចំនួន ១២ ៣០០ ០០០លីត្រ ស្មើនឹង២២,៣៦% នៃផែនការចំនួន ៥៥ ០០០ ០០០ លីត្រ ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ កើនឡើងចំនួន ២០០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ៥៩៩ករណី ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ៨៨ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៥៥៧ករណី និងសមុទ្រចំនួន ៤២ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់អនុវត្តបានចំនួន ២ ៤៦៥តោន ស្មើនឹង១៦,៤៣% នៃផែនការចំនួន ១៥ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ កើនឡើងចំនួន ១៥តោន

- ផលនេសាទកែច្នៃអនុវត្តបានចំនួន ១ ០១០តោន ស្មើនឹង២០,២០% នៃផែនការចំនួន ៥ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ កើនឡើងចំនួន ១០តោន។

### ៥.៦ ការប្រមូលថវិកា

ចំណូលពីសេវាផ្សេងៗក្នុងវិស័យជលផលបានចំនួន ៩៣ ១១៦ ០៨០រៀល ស្មើនឹង៣,១១% នៃផែនការចំនួន ២ ៩៩៤ ០០០ ០០០រៀល ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ១១៤ ០៩៦ ៩៩២រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- បានចុះធ្វើអធិការកិច្ចលើការដឹកនាំ គ្រប់គ្រង និងពិនិត្យលើចំណុចខ្វះខាតមួយចំនួនរបស់វិទ្យាស្ថានស្រាវជ្រាវ-កម្ពុជា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង តាកែវ និងព្រៃវែង

- បានទទួលពាក្យបណ្តឹងចំនួន ២ករណី

- បានទទួលការឯកភាពពីឯកឧត្តមរដ្ឋមន្ត្រីលើសំណើសុំគោលការណ៍អនុញ្ញាតរៀបចំទទួលពាក្យបណ្តឹងតាមរយៈគេហទំព័ររបស់អគ្គាធិការដ្ឋាន

- បានចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ៤៨លើក

- បានធ្វើរបាយការណ៍លម្អិតជូនឯកឧត្តមរដ្ឋមន្ត្រីអំពីចំណុចល្អ ចំណុចខ្វះខាតត្រូវកែលម្អ និងមានវិធានការចំពោះអង្គភាពបានចុះធ្វើអធិការកិច្ចរួច

- បានចេញលិខិតកែលម្អសរុបចំនួន ៣លិខិត និងអង្គភាពបានទទួលលិខិតណែនាំរួចគឺបានធ្វើការកែលម្អលើចំណុចខ្វះខាតរបស់ខ្លួនគួរកត់សម្គាល់។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ២ ៤៩៦ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ១ ០៦៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៩៨៨ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៤៤៥ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៣ ០៩០ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ១៤៤ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៤៤ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៨៩១នាក់ (ស្រី១ ៤៣៧នាក់) ស្មើនឹង២៤,៣៩% រួមមាន៖
  - \+ អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩១៦នាក់ (ស្រី៨២៤នាក់) ស្មើនឹង២៨,២៥%
  - \+ អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៧៥នាក់ (ស្រី៦១៣នាក់) ស្មើនឹង២០,៦០%

- បានតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ៤៥នាក់ (ស្រី១៣នាក់)

- បានចេញប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ៦នាក់ (ស្រី២នាក់)

- បានចេញប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន ៣នាក់ ផ្ទេរចូលក្នុងក្រសួងចំនួន ៤នាក់ និងផ្ទេរផ្ទៃក្នុងក្រសួងចំនួន ២៩នាក់ (ស្រី៣នាក់)

- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ៣០នាក់ ក្នុងនោះមាន៖ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ១៩នាក់ ច្បាប់ឈប់សម្រាករយៈពេលខ្លីចំនួន ២នាក់ ច្បាប់ឈប់សម្រាកមានធុរៈផ្ទាល់ខ្លួនចំនួន ១នាក់ និងច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ៨នាក់

- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ១៦នាក់

- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលបម្រើការងារវិញមានចំនួន ៧នាក់

- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ៨៨៦នាក់ (ស្រី១៨៨នាក់) ក្នុងនោះ៖

  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ៧៤០នាក់ (ស្រី១៤៨នាក់)

  + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ១៤៦នាក់ (ស្រី៤០នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានរៀបចំ និងបញ្ជូនតារាងសូចនាករ និងគោលដៅសូចនាករនៃគម្រោងថវិកាកម្មវិធីឆ្នាំ២០២០ របស់ក្រសួងជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- រៀបចំសិក្ខាសាលាស្តីពី យន្តការ នីតិវិធី សម្រាប់រៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ (កវស) ៣ឆ្នាំរំកិល ២០២១-២០២៣ នៅខេត្តតាកែវ និងបានបំពេញគម្រោងកម្មវិធីវិនិយោគសាធារណៈ(កវស) ៣ឆ្នាំរំកិលនេះ ទៅក្នុងប្រព័ន្ធរបស់ក្រសួងផែនការ

- បានចូលរួមចុះពិនិត្យ និងប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងបញ្ហាដីរបស់ក្រុមហ៊ុន ហ្គ្រីន រ៉ាប់ប៊ើរ ឌីវេឡុបមេនផ្លេនថេសិន ខូ អិលធីឌី ស្ថិតនៅខេត្តសៀមរាប និងខេត្តព្រះវិហារ។ ចុះពិនិត្យ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងសំណើសុំជួយដោះស្រាយបញ្ហាដីចំនួន ៦៧០ហ.ត របស់ក្រុមហ៊ុន អិន ខេ វេនឈ័រ (ខេមបូឌា) លីមីធីត នៅខេត្តស្វាយរៀង។ ចុះពិនិត្យផ្ទៀងផ្ទាត់ និងប្រមូលទិន្នន័យក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនៅខេត្តកំពត។ ចុះពិនិត្យ និងវាយ-តម្លៃជាក់ស្តែងលើទីតាំងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជីង ហ៊ាង អភិវឌ្ឍន៍ ចំនួន ២៥០ហ.ត នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងលើកសំណើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើករណីសុំរៀបចំអនុបយោគលើផ្ទៃដីទំហំ ៤ ៩៩៥,៦៣ហ.ត ស្ថិតនៅក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ របស់ក្រុមហ៊ុន សាជីវកម្ម ស៊ីជេ ខាំបូឌាចំកាត់

- បានចូលរួមចុះសម្របសម្រួល និងដឹកនាំការប្រមូលទិន្នន័យលើ "ការសិក្សា ខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម ដើម្បីជំរុញទីផ្សារប្រកបដោយបរិយាប័ន្នសម្រាប់កសិករខ្នាតតូចនៅខេត្តបាត់ដំបង កំពង់ធំ សៀមរាប បន្ទាយមានជ័យ មណ្ឌលគិរី រតនគិរី កែប កំពត កោះកុង ព្រះសីហនុ ព្រះវិហារ និងខេត្តកំពង់ស្ពឺ

- បានរៀបចំប្រមូលផ្តុំឯកសារវិនិយោគសម្បទានដីសេដ្ឋកិច្ចតាមបណ្តាក្រុមហ៊ុនដើម្បីថែរក្សាទុក

- បានចុះធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវប្រាំងឆ្នាំ២០១៩-២០២០

- បានចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃចន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងសប្តាហ៍នូវរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញ និងកន្លែងលក់ដុំ ផលិតផលក្នុងបណ្តារាជធានីខេត្តចំនួន ២៥

- បានចូលរួមចុះពិនិត្យ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងសំណើសុំជួយដោះស្រាយបញ្ហាដីចំនួន ៦៧០ហ.ត ដែលបានប្រគល់ឱ្យក្រុមហ៊ុន អិន ខេ វេនឈរ (ខេមបូឌា) លីមីធីត និងបានចូលរួមចុះពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៩ បានចំនួន ៥លើក ស្មើនឹង ៥ខេត្ត រួមមានខេត្តមណ្ឌលគិរី ស្ទឹងត្រែង ស្វាយរៀង កំពង់ចាម និងខេត្តក្រចេះ។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានចុះពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិរបស់គម្រោងជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិ-យាប័ន្នអនុវិស័យជលផល និងផលិតកម្មសត្វរបស់ Livestock Sub-sector Component ក្រោមជំនួយហិរញ្ញប្បទានឥតសំណងសហភាពអឺរ៉ុប និងគម្រោង FAO ស្តីពីគំនិតផ្តួចផ្តើមគ្រប់គ្រងសុខភាពសត្វ-បរិស្ថានអនុតំបន់សម្រាប់ផលិតកម្មសត្វតាមគ្រួសារ (EAHIM)

- បានចុះពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិរបស់គម្រោងជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិ-យាប័ន្នអនុវិស័យជលផល និងផលិតកម្មសត្វរបស់ Fisheies Sub-sector Component ក្រោមជំនួយហិរញ្ញប្បទានឥតសំណងសហភាពអឺរ៉ុបដែលបានបញ្ចប់ និងត្រូវប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ សៀមរាប ព្រះវិហារ ត្បូងឃ្មុំ មណ្ឌលគិរី រតនគិរី តាកែវ និងខេត្តកំពត

- បានអនុវត្តប្រមូលចំណូលទឹកប្រាក់សរុបចំនួន ៧ ៣៦១ ២០៨ ៧៨៣រៀល

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធ NRMIS សរុបទឹកប្រាក់ចំនួន ៥ ៧៤៨ ២៨០ ៩៩២រៀល

- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ១៩ ៣២៩ ០៧៦ ១២២រៀល

- បានចុះពិនិត្យកែលម្អការអនុវត្តប្រមូលចំណូលឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ និងខេត្តស្ទឹងត្រែង

- បានទទួលលិខិតសំណើសុំដកប្រាក់កក់ពីក្រុមហ៊ុនចំនួន ២

- បានទទួលបង្កាន់ដៃបង់ប្រាក់ថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ១៤

- បានចុះពិនិត្យ និងវាយតម្លៃជាក់ស្តែងសម្រាប់គណនាថ្លៃសម្បទានដីសេដ្ឋកិច្ចត្រូវបង់ចូលថវិការដ្ឋចំនួន ៣៤ក្រុមហ៊ុន

- បានចុះពិនិត្យវាយតម្លៃបញ្ជាប់សុពលភាពស្តីពីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពឃ្លាំងដាក់គ្រឿងចក្រ ផ្ទះសំណាញ់ Nethouse លានហាលស្រូវ អាងស្តុកទឹកអាកាស អាងស្តុកទឹកបឋមនៅតាមមណ្ឌលអភិវឌ្ឍន៍កសិកម្ម និងស្ថានីយពិសោធន៍កសិកម្មចំនួន ៨កន្លែងរបស់អគ្គនាយកដ្ឋានកសិកម្ម ខេត្តកណ្តាល តាកែវ ស្វាយរៀង និងខេត្តឧត្តរមានជ័យ។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានបើកវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំសវនកម្មបច្ចេកវិទ្យាព័ត៌មាន

- បានរៀបចំកែសម្រួលផែនការថវិកាតាមកញ្ចប់ថវិកានៃវិចារណកម្មចំណាយ

- បានចុះធ្វើសវនកម្មតាមផែនការសកម្មភាពចំនួន ៩អង្គភាព គឺ៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ មណ្ឌលគិរី កំពង់ស្ពឺ កំពង់ឆ្នាំង ឧត្តរមានជ័យ ព្រះវិហារ គម្រោងជំរុញផលិតកម្មស្បៀង និងគម្រោងកសាងសមត្ថភាពដែលអាចសម្រេចបានតាមរយៈការពង្រឹងបច្ចេកវិទ្យាថាមពលកកើតឡើងវិញនៅតំបន់ជនបទ។ សរុបបានចុះធ្វើសវនកម្មចំនួន ៩សវនដ្ឋាន ស្មើនឹង១៨,៣៦% នៃផែនការចំនួន ៤៩សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន ៤៩អនុសាសន៍។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំ Meeting Supporting Climate-Proofing Rice Production System (CRiPS) Based on Nuclear Application-PhaseII នៅ Austria

- បានរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកសិកម្ម និងកិច្ចប្រជុំលើកទី១៥ របស់គណៈកម្មការវិធានការភូតគាមអនាម័យ

- បានទទួលជួបគណៈប្រតិភូកូរ៉េ

- បានប្រជុំជាមួយ USAID ស្តីពី Meeting of the Joint Steering Committee for Agriculture (JSC-A)

- បានប្រជុំពិភាក្សាលើទស្សនទានគម្រោងដើម្បីស្នើទៅភាគីអ៊ីស្រាអែល

- បានធ្វើសំណើចាត់ថ្នាក់ដឹកនាំ និងមន្ត្រីចំនួន ៤នាក់ ដើម្បីចូលរួមក្នុងគណកម្មការរៀបចំកិច្ចប្រជុំក្រុមការងារអាស៊ានឆ្នាំ២០២០

- បានចូលរួមជាមួយលេខាធិការដ្ឋានគម្រោងនៃលេខាធិការអាស៊ានក្នុងការចុះពិនិត្យការរៀបចំ និងដំណើរការវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងការអនុវត្តបច្ចេកវិទ្យាកៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែរ

- បានសម្របសម្រួលធ្វើលិខិតផ្តល់យោបល់លើរបាយការណ៍នៃកិច្ចប្រជុំចរចាលើកទី១ស្តីពីការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននៃ Sub-Working Group on SPS

- បានរៀបចំលិខិតអញ្ជើញប្រជុំពិនិត្យមាត្រានីមួយៗនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន នៃអនុក្រុមការងារអនាម័យ និងភូតគាមអនាម័យ

- បានធ្វើសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអាស៊ាន

- បានប្រជុំពិភាក្សាលើព័ត៌មានអំពីវឌ្ឍនភាព និងតួអង្គពាក់ព័ន្ធរួមជាមួយតួនាទី ភារកិច្ចក្នុងខ្សែច្រវាក់តម្លៃផលិតកម្មស្វាយចន្ទី និងការឆ្លើយតបនឹងសំណូមពររបស់ភាគីជប៉ុន ជាពិសេសក្រុមហ៊ុនឯកជនទាក់ទងនឹងខ្សែច្រវាក់តម្លៃផលិតកម្មស្បៀង។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦៧ក្រុមហ៊ុន សរុបចំនួន ៦៣៨មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦១ក្រុមហ៊ុន

- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៩ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ៣ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ២១ក្រុមហ៊ុន សរុបចំនួន ១២៥សំណាក។

### ១៣.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- បានបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករអ្នកលក់ដុំ លក់រាយសម្ភារកសិកម្មចំនួន ៣ខេត្ត គឺនៅខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តរតនគិរី ដែលមានអ្នកចូលរួមចំនួន ១៥៥នាក់។

### ១៣.៤ ការងារអនុវត្តច្បាប់

- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មនៅខេត្តចំនួន៤គឺ ខេត្តសៀមរាប បន្ទាយ-មានជ័យ ប៉ៃលិន និងខេត្តបាត់ដំបងចំនួន ២៩ដេប៉ូ និងពិន័យអន្តរការណ៍ ៧ករណី។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- បានបញ្ចូលតំណភ្ជាប់គេហទំព័ររបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងគេហទំព័រក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានតាមដានទិន្នន័យ និងសម្អាត Catch នៅលើ Cloud Server នៃគេហទំព័រទាំង៤១
- បានធ្វើបច្ចុប្បន្នភាពនៃគេហទំព័រ ចុះបណ្តុះបណ្តាល តាមដានការប្រើប្រាស់ និងបង្ហាញមុខងារប្រើប្រាស់ថ្មីៗលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៦គឺ ខេត្តសៀមរាប កំពង់ធំ កំពង់ស្ពឺ កោះកុង តាកែវ និងខេត្តព្រះសីហនុ
- បានចុះប្រមូលទីតាំងដំណាំស្រូវប្រាំងចំនួន ៣ខេត្ត គឺខេត្តស្វាយរៀង តាកែវ និងខេត្តព្រៃវែង ដើម្បីរៀបចំផែនទីដំណាំកសិកម្មសម្រាប់បញ្ចូលក្នុងគេហទំព័រព័ត៌មានភូមិសាស្ត្រកសិកម្ម
- បន្តការធ្វើបច្ចុប្បន្នភាពលើគេហទំព័របណ្ណាល័យកសិកម្ម និងជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាលការប្រើ-ប្រាស់អំពីគេហទំព័របណ្ណាល័យកសិកម្ម និងពិនិត្យអំពីការរៀបចំបណ្ណាល័យរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៥គឺ ខេត្តព្រះវិហារ ក្រចេះ សៀមរាប កណ្តាល និងខេត្តស្វាយរៀង។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានចុះសម្ភាសន៍គ្រួសារកសិករសម្រាប់សិក្សា និងវិភាគសេដ្ឋកិច្ចគ្រួសារកសិករនៅភូមិដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់
- បានចុះទៅផលិតខ្សែ Video បទយកការណ៍ចំនួន ៦ ស្តីពីដំណាំបន្លែ គ្រីន បេ ប៉ិលីស ដំណាំទំពាំងផ្អែម ការចិញ្ចឹមមាន់យកកូនលក់ ការដាំដុះបន្លែប្រើប្រាស់ប្រព័ន្ធដំណក់ទឹក ជីវភាពរីកចម្រើនដោយមុខរបរចិញ្ចឹមមាន់ និងភាពជោគជ័យរបស់កសិករក្នុងការដាំដុះបន្លែតាមបច្ចេកទេសកសិកម្មធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
- បានធ្វើការសហការជាមួយស្ថានីយទូរទស្សន៍ជាតិ និងផលិតឯកសារនាទីចុះស្រែជាមួយកសិករចំនួន ២ ស្តីពីបច្ចេក-ទេសចិញ្ចឹមមាន់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការដាំដុះបន្លែបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ១៧សម្រាប់ធ្វើការផ្សព្វផ្សាយ។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បានចុះសិក្សា និងប្រមូលទិន្នន័យបឋមអំពីខ្សែច្រវាក់តម្លៃផលិតផលម្រេចនៅខេត្តកំពង់ចាម
- បានចុះសិក្សាស្វែងយល់ស្ថានភាពទូទៅនៃខ្សែច្រវាក់តម្លៃស្វាយចន្ទីនៅខេត្តកំពង់ធំ
- បានពិនិត្យឡើងវិញនូវវិធីសាស្ត្រមួយចំនួនសម្រាប់ការវិភាគរកវត្តមានបាក់តេរី ដូចជា បាក់តេរីសរុប សាល់ម៉ូ-ណេឡា អ៊ីកូឡាយ បង្កជំងឺគ្រុនពោះវៀន និងពពួកបាក់តេរីផ្សិត
- បានចុះពិនិត្យទីផ្សារបោះដុំចំនួន ៣កន្លែងដែលមានសក្តានុពលក្នុងការជ្រើសរើសសំណាកមកវិភាគ
- បានវិភាគរកលោហៈធ្ងន់ (អាសេនិច) នៅក្នុងបន្លែស្រស់ ដូចជា ត្រកួន ព្រលិត ភ្លៅកង្កែប ផ្កាខាត់ណា និងអង្គរ

- បានសិក្សា និងវិភាគរកសមាសធាតុ NPK នៅក្នុងជីគីមីកសិកម្មដែលកំពុងចរាចរណ៍លើទីផ្សារ
- បានសិក្សា និងវិភាគរកសមាសធាតុមេតាណុលក្នុងអាល់កុល និងស្រាសដែលកំពុងចរាចរណ៍លើទីផ្សារ
- បានកសាងគម្រោងវិភាគកាកសំណល់គីមីថ្នាំកសិកម្ម លោហៈធ្ងន់ មីកូតុកស៊ីន និងសារធាតុពុលផ្សេងៗទៀត ផលិតផលកសិកម្ម និងចំណីអាហារ
- បានចុះសិក្សា និងប្រមូលទិន្នន័យបឋមអំពីខ្សែច្រវាក់តម្លៃផលិតផលម្រេចនៅខេត្តព្រះវិហារ
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រថ្មីៗនៃការវិភាគគុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ
- បានចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសក្រោយការប្រមូលផលនៃផលិតផលកសិកម្មនៅខេត្តស្ទឹងត្រែង
- បានចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តកំពត។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានបន្តការអភិរក្សពូជដំណាំចំនួន ៣៨ប្រភេទ រួមមាន ស្រូវចំនួន ៦ ៧៧៦បញ្ជីក/សំណាក និងដំណាំផ្សេងៗ ចំនួន ៣៧ប្រភេទ សរុបចំនួន ២ ៣៣៥បញ្ជីក/សំណាក សរុបទាំងអស់ចំនួន ៩ ១១១បញ្ជីក/សំណាក និងបានពិនិត្យសៀវភៅកាតាឡុកដំណាំម្ទេសចប់សម្រាប់បោះពុម្ព
- បានធ្វើពិសោធន៍ចំនួន ៤០ប្រភេទ នៅ១៣៣កន្លែង ក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន ៥៥កន្លែង។ ធ្វើទិវាស្រែបង្ហាញចំនួន ៩លើក មានកសិករចូលរួមចំនួន ៣៣៥នាក់ (ស្រី១៩៣នាក់) និងបើកវគ្គបណ្តុះបណ្តាលកសិករចំនួន ៧លើក មានកសិករចូលរួមចំនួន ២៤០នាក់ (ស្រី១៣៩នាក់)
- បានបើកវគ្គបណ្តុះបណ្តាលចំនួន ១វគ្គ មានអ្នកចូលរួមសរុបចំនួន ២៦នាក់ ដឹកនាំនិស្សិតចុះធ្វើកម្មសិក្សា សរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រចំនួន ១រូបមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
- បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្រៅប្រទេសចំនួន ១លើក ដែលមានថ្នាក់ដឹកនាំ និងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន ២នាក់ និងមន្ត្រីសរុបចំនួន ៤រូបទៀត បាននិងកំពុងបន្តការសិក្សាថ្នាក់បណ្ឌិតចំនួន ២រូប និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២រូប នៅប្រទេសកូរ៉េ ជប៉ុន និងប្រទេសចិន
- បានបោះពុម្ពឯកសារឡើងវិញចំនួន ៧ ៤២០ច្បាប់ និងបែងចែកឯកសារសរុបចំនួន៣ ៧៦៤ច្បាប់។ អ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យារបស់វិទ្យាស្ថានតាមរយៈគេហទំព័រ http://www.cardi.org.kh មានចំនួនសរុប ២៤៦ ៧១២នាក់
- បានចូលរួមសន្និបាត និងកិច្ចប្រជុំនានានៅក្នុងប្រទេសចំនួន ២៧លើក ស្ថាប័ន/អង្គភាពនានាចំនួន ៨លើក និងទទួលជួបភ្ញៀវជាតិនិងអន្តរជាតិនៅវិទ្យាស្ថានចំនួន ៣លើក
- បញ្ចប់ការបញ្ចូលនិងវិភាគទិន្នន័យពិសោធន៍ទាំងអស់ដែលបានធ្វើនារដូវវស្សាឆ្នាំ២០១៩កន្លងមកទាំងអស់
- បន្តថែទាំតាមដាននិងស្រង់ទិន្នន័យរាល់ពិសោធន៍រដូវវស្សានិងរដូវប្រាំង២០១៩-២០២០ ព្រមទាំងបញ្ចូលទិន្នន័យ និងធ្វើការវិភាគជាបណ្តើរៗរាល់ពិសោធន៍ណាដែលចប់សព្វគ្រប់
- រៀបចំពិធីការនិងសម្ភារសម្រាប់ពិសោធន៍រដូវវស្សាឆ្នាំ២០២០។

### ១៧.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានត្រួតពិនិត្យទូទៅការថែទាំ និងការពារឡូត៍ពិសោធន៍
- បានស្រង់ទិន្នន័យជ័រកៅស៊ូឡូត៍ពិសោធន៍ក្លូន IRAA01 IRAA10 និង SSCT01
- បានថែទាំច្បារពូជកៅស៊ូដើម្បីផ្គត់ផ្គង់មែកពូជដល់ការពិសោធន៍ស្រាវជ្រាវ
- បានថែទាំកូនកៅស៊ូស៊ីដលីង ច្បារបង្កាត់ពូជ និងGSET02
- បានវាស់ទំហំដើមកៅស៊ូឡូត៍ពិសោធន៍ចំនួន ៣ឡូត៍ គឺ IRAA05 IRAA10 និង SSCT01
- បានស្រង់ទិន្នន័យជំងឺ *Oidium* ចំនួន ១០ឡូត៍ពិសោធន៍
- បានសិក្សាមាឌឈើកៅស៊ូតាមក្លូននីមួយៗនៅឡូត៍សោធន៍ក្លូន IRAA01 និង IRAA02
- បានថែទាំកូនកៅស៊ូបំបៅរួចដែលបានមកពីក្រុមហ៊ុនចម្ការកៅស៊ូ SOCFIN-KCD និង RRI-CATAS
- បានស្រង់ទិន្នន័យទឹកជ័រលើចម្ការពិសោធន៍សក្តានុពលទិន្នផលលើប្រព័ន្ធចង្វាក់ចៀរជ័រ (d3 d4) ចំនួន ៩ចម្ការពិសោធន៍ ប្រព័ន្ធចង្វាក់ចៀរបង្វិល (d3 d4 d5 d6) ចំនួន ២ចម្ការពិសោធន៍
- បានវាស់ទំហំដើមតាមការលូតលាស់លើចម្ការពិសោធន៍ចំនួន ៣គឺ IRAE07 IRAE17 និង KRAE03
- បានត្រួតពិនិត្យការស្រោចស្រពកៅស៊ូនៅចម្ការពិសោធន៍នៅឡូត៍ ៤២DNW
- បានថែទាំឡូត៍កៅស៊ូចៀរជ័រដូចជាលាបថ្នាំរំញោច និងលាបខ្លាញ់គោលើដើមកៅស៊ូចៀរជ័រ
- បានស្រង់ទិន្នន័យដើមស្ងួតមុខចៀរ (TPD) ចម្ការពិសោធន៍ IRAE0។

## ១៧.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- ក្នុងដំណាក់កាលនៃការទប់ស្កាត់ការរីករាលដាលនៃជំងឺផ្លូវដង្ហើមថ្មី សាកលវិទ្យាល័យភូមិន្ទកសិកម្មបានយកចិត្តទុកដាក់ផ្សព្វផ្សាយ និងផ្គត់ផ្គង់សម្ភារអនាម័យ ជូនដល់គ្រប់អង្គភាព និងមហាវិទ្យាល័យដើម្បីអនុវត្តន៍តាមវិធានការការពាររបស់ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និងកីឡា

- ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានបានបញ្ចប់កម្មវិធីសិក្សាឆមាសទី១ របស់ខ្លួនជាស្ថាពរ។ ចំណែកនិស្សិតឆ្នាំទី២ និងទី៣ បានដំណើរការសិក្សាឆមាសទី២របស់ខ្លួន

- និស្សិតឆ្នាំទី២ ជំនាន់ទី១២ ចំនួន ១១៨នាក់ និងនិស្សិតសាកលវិទ្យាល័យ Melbourne នៃប្រទេសអូស្ត្រាលីចំនួន៤នាក់ លោកគ្រូ អ្នកគ្រូ មន្ត្រីរាជការនៃមហាវិទ្យាល័យវេជ្ជសាស្ត្រសត្វចំនួន ១៥នាក់ និងសាស្ត្រាចារ្យអូស្ត្រាលី ១នាក់ ចុះធ្វើកម្មសិក្សាអនុវត្តវិធីសាស្ត្រវាយតម្លៃរោគសាស្ត្រសត្វផ្តល់ចំណេះដឹងពីវិធានជីវសុវត្ថិភាព ការការពារជំងឺឆ្កែឆ្កួតដល់កសិករ សិស្សសាលា និងអនុវត្តការចាក់វ៉ាក់សាំងការពារជំងឺឆ្កែឆ្កួតដល់ឆ្កែឆ្មា ចាក់ថ្នាំទំលាក់បរាសិត និងផ្តល់វីតាមីនដល់សត្វនៅខេត្តកំពង់ឆ្នាំង

- បានរៀបចំពិធីអបអរសាទរទិវានារីអន្តរជាតិ៨មីនា ខួបលើកទី១០៩ ក្រោមប្រធានបទមានសន្តិភាពមានការលើកកំពស់សមភាពយេនឌ័រ និងពិធីបំពាក់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

- បានចូលរួមពិធីជូនដំណើរសិស្សនិស្សិតទទួលអាហារូបករណ៍រដ្ឋាភិបាលជប៉ុនចំនួន ២៩នាក់ សម្រាប់ឆ្នាំ២០២០ នៅស្ថានទូតជប៉ុនប្រចាំកម្ពុជាក្រោមអធិបតីភាព ឯកឧត្តមឯកអគ្គរាជទូតជប៉ុន និងឯកឧត្តម ពិត ចំណាន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងនោះ មាននិស្សិតសាកលវិទ្យាល័យចំនួន ១រូប បានទទួលអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

- បានចូលរួមពិធីចុះហត្ថលេខាទទួលមូលនិធិបន្ថែមពីស្ថានទូតជប៉ុនលើគម្រោង ERECON ដើម្បីអនុវត្តបន្តនៅខេត្តកំពង់ចាម ដោយសហការជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានកសិកម្មកំពង់ចាម និង មន្ទីរកសិកម្មខេត្តកំពង់ចាម

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រនៃការវាយតម្លៃរោគរាតត្បាតសត្វដែលមានការចូលរួមពីសាស្ត្រាចារ្យសាកលវិទ្យាល័យ Melbourne ប្រទេសអូស្ត្រាលី ដើម្បីពង្រឹងការសិក្សា និងការស្រាវជ្រាវរបស់មន្ត្រីសាស្ត្រាចារ្យ និងនិស្សិត ជាពិសេសមហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ

- បានរៀបចំបទបង្ហាញស្តីពីមូលដ្ឋានគ្រឹះនៃការផលិតវ៉ាក់សាំង ដោយ លោក ពុត សៅ A Post-Doctoral Researcher at Combinatorial Tumor Immunotherapy Research Center and Clinical Vaccine R&D Center of Chonnam National University សាធារណរដ្ឋកូរ៉េ

- បានរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសស្តីពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រសម្រាប់វិស័យព្រៃឈើក្នុងគោលបំណងបង្កើនសមត្ថភាព និងលើកទឹកចិត្តដល់សិក្ខាកាមដើម្បីធ្វើការស្រាវជ្រាវលើជំនាញពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ

- បានរៀបចំសិក្ខាសាលាស្តីពីលក្ខណៈជីវសាស្ត្រ បច្ចេកទេសផលិតពូជ និងចិញ្ចឹមត្រីឆ្តង់ ដោយលោកសាស្ត្រាចារ្យបណ្ឌិត Mike Rimmer ជាសមាជិកស្រាវជ្រាវជាន់ខ្ពស់ពីសាកលវិទ្យាល័យ Sunshine Coast ប្រទេសអូស្ត្រាលី ដើម្បីពង្រឹងការសិក្សានិងស្រាវជ្រាវរបស់មន្ត្រីសាស្ត្រាចារ្យ និងនិស្សិត

- បានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងរួមគ្នារវាងក្រុមហ៊ុន iL Brille របស់ជប៉ុន និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ស្តីពីការចម្រាញ់ប្រូតេអ៊ីនពីសំបុកដង្កូវនាង និងការវិភាគគុណភាព ដើម្បីយកមកផលិតជាគ្រឿងសំអាង ឱសថ និងអាហារ ដែលគាំទ្រថវិកាដោយអង្គការ JICA

- បានទទួលមីក្រូទស្សន៍សម្រាប់ពិនិត្យផ្សិតបង្កជំងឺលើកៅស៊ូ និងឧបករណ៍បន្សុទ្ធទឹកចំនួន មួយគ្រឿងពីគម្រោង CESAIN សម្រាប់ពង្រឹងការសិក្សា និងស្រាវជ្រាវរបស់មន្ត្រីសាស្ត្រាចារ្យ និងនិស្សិត

- បានជួបពិភាក្សាជាមួយ អង្គការយូនីដូ (United Nations Industrial Development Organization-UNIDO) ដើម្បីកិច្ចសហប្រតិបត្តិការបង្កើតវេទិកាបច្ចេកវិទ្យាអាហារទាក់ទងនឹងផលិតផលនេសាទទឹកសាប និងសមុទ្រ ក្រោមគម្រោងអភិវឌ្ឍន៍ CAPFish-Post-harvest Fisheries Development។

**១៧.៤ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប**

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ១ ០៨៨នាក់ (ស្រី៤៥៤នាក់) លើជំនាញៈ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី

- បានដំណើរការបង្រៀននិស្សិតគ្រប់ជំនាញពីឆ្នាំទី១ដល់ឆ្នាំទី៤ ប្រកបដោយភាពរលូន

- បានពិនិត្យ និងកែលម្អកម្មវិធីសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ បរិញ្ញា និងបរិញ្ញារងបន្ទាប់ពីទទួលកម្មវិធីសិក្សារបស់ដេប៉ាតឺម៉ង់គ្រប់ជំនាញ

- បានរៀបចំកិច្ចប្រជុំគ្រប់ដេប៉ាតឺម៉ង់ចំនួន ១៣ ដោយលើកយកកម្មវិធីសិក្សាថ្នាក់បរិញ្ញា និងបរិញ្ញារង ដើម្បីពិនិត្យ និងកែលម្អគម្រោងមុខវិជ្ជានីមួយៗចំនួន ១៣លើក

- បានចូលរួមការតាំងពិព័រណ៍កសិកម្ម និងបច្ចេកវិទ្យាលើកទី៨ នៅសាកលវិទ្យាល័យ Rajamangala ប្រទេសថៃ ១លើក មានថ្នាក់ដឹកនាំ និងមន្ត្រីចំនួន ៥នាក់

- បានទៅទស្សនកិច្ចសិក្សាកសិដ្ឋានចិញ្ចឹមគោយកទឹកដោះក្នុងឱទ្យាន តេជោសែន ឫស្សីត្រឹប ខេត្ត ព្រះវិហារ ចំនួន ១លើក

- បន្តសហការជាមួយ Vitrosyste ក្រុមហ៊ុនប្រទេសកូរ៉េ ជម្រុញការស្រាវជ្រាវផ្នែកជាលិកាវប្បកម្ម

- បន្តសហការជាមួយ Cambodia-Japan Research Center for Agriculture របស់វិទ្យាស្ថានជាតិ ជម្រុញការស្រាវជ្រាវលើដំណាំចេកអំបូងពណ៌លឿងរបស់ជប៉ុនក្នុងផ្ទះសំណាញ់

- បន្តសហការជាមួយក្រុមហ៊ុនចិនពិសោធន៍លើការចិញ្ចឹមត្រីបបែល

- បានដឹកនាំនិស្សិតដាំបន្លែពិសោធន៍មានដូចជា ស្ពៃក្តោប ស្ពៃចង្កឹះ តាំងអោ ត្រសក់ និងពោតដំណើប។

**១៧.៥ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម**

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៩-២០២០ សរុបចំនួន ៧១៩នាក់ (ស្រី២៨៤នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិង អភិវឌ្ឍន៍ជនបទ

- បានរៀបចំពិសោធន៍ជីសរីរាង្គលើការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- បានរៀបចំសាកល្បងផលិតមេជី Lacto Bacellus និងពិសោធន៍ឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្តោប និងស្រូវនៅខេត្តកំពង់ចាម

- បានរៀបចំពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ទឹកលើអាងចិញ្ចឹមត្រីក្នុងកន្លែងពិសោធន៍ជលផលរបស់សាលា

- បានពិសោធន៍ប្រៀបធៀបការបំផ្លាញរបស់កន្លាតចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម

- បានបន្តការងារមន្ទីរពិសោធន៍ចិញ្ចឹម និងភ្ញាស់ដង្កូវនាងព្រៃ

- បានសហការជាមួយលោកសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យជាតិកាង វ៉ុន ចុះធ្វើការស្រាវជ្រាវប្រភេទរុក្ខជាតិនៅកម្ពុជា និងចម្រាញ់ប្រេងរុក្ខជាតិចេញពីម្រេចបង្កើតបានជាទឹកអប់

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផល លើដំណាំស្វាយចន្ទី ប៉េងប៉ោះ ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងនៅទូទាំងប្រទេសបានបញ្ចប់ ដោយសម្រេចបានចំនួន ៥៩៧ ៥០៨ហ.ត ស្មើនឹង១៣០,០១% នៃផែនការចំនួន ៤៥៩ ៥៩៤ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មនៅក្នុងរដូវវស្សាឆ្នាំ២០២០ ដែលនឹងឈានចូលមកដល់នាពេលដ៏ខ្លីខាងមុខនេះ
- បន្តធ្វើការពិនិត្យសន្និធិស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តវិធានការបន្ទាន់ដើម្បីដោះស្រាយបញ្ហានៃការធ្លាក់ចុះថ្លៃផលិតផលផ្លែស្វាយ
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មនិងបសុព្យាបាល

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- បន្តអនុវត្តការបង្កាត់ពូជជ្រូកដោយសិប្បនិម្មិត។

### ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានជ្រួតជ្រាបដល់មូលដ្ឋាន ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងទំនាក់ទំនងទ្វេភាគី និងពហុភាគីសម្រាប់ការបណ្តុះ-បណ្តាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃ។

### ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

### ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាម

រាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**